ខ្មែរPrEP

# ការពិត ៥ ចំណុចដែលអ្នកគួរដឹងអំពីប្រិប PrEP

USAID FROM THE AMERICAN PEOPLE · PEPFAR U.S. President's Emergency Plan for AIDS Relief · UNAIDS · fhi360 THE SCIENCE OF IMPROVING LIVES · LINKAGES Across the Continuum of HIV Services for Key Populations

## ១ តើអ្វីទៅជា PrEP?

PrEP ( ពាក្យពេញគឺ Pre-Exposure Prophylaxis ) ជាការប្រើឱសថក្នុងការបង្ការកុំឱ្យឆ្លងមេរោគអេដស៍ ដោយលេបឱសថនោះ ( ជាប្រភេទឱសថប្រឆាំងមេរោគអេដស៍រួមបញ្ចូលគ្នា ) ជារៀងរាល់ថ្ងៃ។ PrEP ជាការបង្ការដល់អ្នកដែលមិនមានផ្ទុកមេរោគអេដស៍ ប៉ុន្តែមានការប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍។ ភស្តុតាងនានាបានបង្ហាញថា នៅពេលអ្នកលេបឱសថនេះទៀងទាត់ និងត្រឹមត្រូវ វានឹងជួយកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍ស្ទើរដល់កម្រិតសូន្យ។ គួរកត់សម្គាល់ថា PrEP មិនបង្ការការមានផ្ទៃពោះឬជំងឺកាមរោគផ្សេងៗឡើយ។



# ២ តើនរណាខ្លះដែលត្រូវប្រើប្រាស់ PrEP ?

PrEP គឺសម្រាប់អ្នកដែលមិនមានផ្ទុកមេរោគអេដស៍ ដែលមានការប្រឈមខ្ពស់នឹងការឆ្លងមេរោគអេដស៍ ឬការប្រើប្រាស់គ្រឿងញៀន។ ហេតុផលជាច្រើនដែលអ្នកគួរពិចារណាប្រើប្រាស់ PrEP មានដូចជា៖

- អ្នកមិនបានប្រើប្រាស់ស្រោមអនាម័យរាល់ពេលដែលអ្នករួមភេទ និងអ្នកមានដៃគូច្រើន។
- អ្នកមានការរួមភេទជាមួយដៃគូច្រើនក្នុងរយៈពេល ៦ ខែចុងក្រោយ។
- អ្នកមានដៃគូរួមភេទដែលមានផ្ទុកមេរោគអេដស៍ ឬប្រឈមខ្ពស់នឹងការឆ្លងមេរោគអេដស៍។
- អ្នកមានការរួមភេទជាមួយនឹងដៃគូដែលចាក់គ្រឿងញៀនហើយប្រើប្រាស់ឧបករណ៍សម្រាប់ចាក់រួមគ្នាជាមួយអ្នកផ្សេង។



## ៣ តើ PrEP អាចបង្ការបាន យ៉ាងដូចម្ដេច?

PrEP មិនផ្ដល់ការបង្ការបាន ១០០% នោះទេ ប៉ុន្តែផ្ដល់ប្រសិទ្ធភាពខ្ពស់ក្នុងការប្រឆាំងនឹងការឆ្លងមេរោគអេដស៍។ នៅក្នុងការសិក្សាថ្មីៗ PrEP បានបង្ហាញពីការកាត់បន្ថយការប្រឈមនឹងការឆ្លងមេរោគអេដស៍តាមការរួមភេទរហូតដល់៩៦% នៅពេលដែលប្រើប្រាស់បានត្រឹមត្រូវតាមការណែនាំ។ ដើម្បីជៀសវាងការឆ្លងមេរោគអេដស៍ និងមេរោគបង្កជំងឺកាមរោគផ្សេងៗ អ្នកគួរប្រើ PrEP រួមជាមួយស្រោមអនាម័យ។

## ៤ នៅពេលកំពុងប្រើ PrEP តើត្រូវប្រើស្រោមអនាម័យដែរឬទេ?

PrEP មានប្រសិទ្ធភាពសម្រាប់តែការបង្ការការឆ្លងមេរោគអេដស៍ប៉ុណ្ណោះ។ PrEP មិន

ជួយការពារអ្នកពីមេរោគបង្កជំងឺកាមរោគផ្សេងៗ (ដូចជា៖ ជំងឺស្វាយ ជំងឺប្រមេះទឹកបាយ និងជំងឺ chlamydia) ជំងឺរលាកថ្លើម និង ការមានផ្ទៃពោះដោយមិនបានព្រាងទុកនោះទេ។ ហេតុដូច្នេះ ត្រូវប្រើទាំង PrEP និងស្រោមអនាម័យ ដើម្បីបង្ការឱ្យបានគ្រប់គ្រាន់ពីការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគ ជំងឺរលាកថ្លើម និងការមានផ្ទៃពោះដោយមិនបានព្រាងទុក។

## ៥ តើខ្ញុំអាចប្រើ PrEP រយៈពេល តែ ១ថ្ងៃ បានដែរឬទេ?

អ្នកគួរប្រើ PrEP យ៉ាងហោចណាស់រយៈពេលមួយសប្តាហ៍ ជារៀងរាល់ថ្ងៃ មុននឹងអាចឱ្យឱសថជ្រាបចូលក្នុងខ្លួនបានគ្រប់គ្រាន់ដើម្បីការពារខ្លួនអ្នកពីការឆ្លងមេរោគអេដស៍។



# ៦ តើគួរប្រើប្រាស់ PrEP យ៉ាងដូចម្តេច?

អង្គការសុខភាពពិភពលោកណែនាំឱ្យប្រើប្រាស់ PrEP ម្តងក្នុងមួយថ្ងៃជារៀងរាល់ថ្ងៃ។ ការលេបថ្នាំ PrEP ជារៀងរាល់ថ្ងៃ គឺមានសុវត្ថិភាព និងមានភាពងាយស្រួល ហើយនឹងផ្តល់នូវការបង្ការពីការឆ្លងមេរោគអេដស៍ដែលប្រសើរបំផុត។

- PrEP អាចលេបបានជាមួយ ឬមិនជាមួយចំណីអាហារ។
- PrEP អាចលេបបាន នៅពេលផឹកគ្រឿងស្រវឹង។

**សូមទូរស័ព្ទមកលេខខាងក្រោម ដើម្បីទទួលបានថ្នាំ PrEP ដោយឥតគិតថ្លៃនៅគ្លីនិក ឈូកស ឬ ចូលមើលគេហទំព័រគ្លីនិកដើម្បីទទួលបានព័ត៌មានលំអិត**

092 266 530 | 081 568 477 | 060 666 219

www.chhouksarclinic.com

chhouk Sar Clinic

## ៧ តើត្រូវធ្វើដូចម្តេចបើខ្ញុំភ្លេចលេបថ្នាំ ១កម្រិតដូស?

ប្រសិនបើអ្នកលេបថ្នាំ PrEP រាល់ថ្ងៃ ហើយអ្នកភ្លេចលេបថ្នាំ១កម្រិតដូសអ្នកនៅតែមានការការពារដែលមានកម្រិតខ្ពស់។

ប្រសិនបើអ្នកភ្លេចលេបថ្នាំ១កម្រិតដូស អ្នកគ្រាន់តែលេបភ្លាមនៅពេលអ្នកនឹកឃើញ។ ជាឧទាហរណ៍ ប្រសិនបើអ្នកលេបថ្នាំ PrEP ពេលព្រឹក ប៉ុន្តែថ្ងៃមួយអ្នកភ្លេច ហើយនឹកឃើញនៅម៉ោង ១០យប់ អ្នកអាចលេបភ្លាម ហើយបន្តលេបពេលព្រឹកនៅថ្ងៃបន្ទាប់ដូចធម្មតា។

## ៨ តើមានផលប៉ះពាល់អ្វីខ្លះពីការប្រើ PrEP?

ផលប៉ះពាល់មានដូចជា បញ្ហាក្រពះ ពោះវៀន ការវិលមុខធីងធោង ឬរមាស់។ មានតែមនុស្ស

មួយចំនួនតូចប៉ុណ្ណោះដែលមានរោគសញ្ញាទាំងនេះ។ រោគសញ្ញាទាំងនេះជាធម្មតាកើតឡើងតិចតួច និងបាត់ទៅវិញក្នុងរយៈពេលពីរទៅបីសប្តាហ៍ដំបូង។ សារធាតុថ្នាំមួយក្នុងចំណោមសារធាតុថ្នាំផ្សេងក្នុងសមាសភាគរួមបញ្ចូលគ្នា អាចប៉ះពាល់ដល់មុខងារតម្រងនោម។ អ្នកនឹងត្រូវធ្វើតេស្តមុននឹងចាប់ផ្តើមប្រើ និងត្រូវធ្វើតេស្តពីរ-បីដងទៀតក្នុងមួយឆ្នាំដើម្បីប្រាកដថាគ្រប់យ៉ាងដំណើរការបានល្អ។

## ៦ តើពេលណាខ្ញុំអាចឈប់ប្រើ PrEP បាន?

នៅពេលអ្នកចាប់ផ្តើមប្រើប្រាស់ PrEP មិនមែនបានន័យថា អ្នកនឹងប្រើវារហូតមួយជីវិតនោះទេ។ អ្នកប្រើ PrEP ក្នុងអំឡុងពេលដែលអ្នកប្រឈមនឹងការឆ្លងមេរោគអេដស៍។ ប្រសិនបើស្ថានភាពអ្នកមានការប្រែប្រួល អ្នកគួរប្រឹក្សាជាមួយគ្រូពេទ្យ ឬអ្នកផ្តល់សេវាមុននឹងឈប់ប្រើ PrEP។